ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
**ការិយាល័យអ្នកនាំពាក្យ**

# សេចក្តីបដិសេធ

ថ្មីៗនេះមានបុគ្គល ឬក្រុមខិលខូចបានប្រើប្រាស់ឈ្មោះ និងរូបភាព **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បង្កើតគណនីតេឡេក្រាមក្លែងក្លាយឈ្មោះថា **"CEO. H.E HENG Sour" (@HENG_Souradmin)** និងរូបភាព **ឯកឧត្តមរដ្ឋមន្ត្រី** រួមជាមួយថ្នាក់ដឹកនាំក្រសួងក្នុងកម្មវិធីមួយ មកប្រើជារូបប្រូហ្វាលក្រុមតេឡេក្រាមឈ្មោះ "ប្រាក់ចំណេញ ROI ប្រចាំថ្ងៃរបស់ OCIC ការវិនិយោគ" ដែលអាចបង្កការភាន់ច្រឡំដល់សាធារណជនថា ជារបស់ **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ការិយាល័យអ្នកនាំពាក្យ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនសាធារណជនថា គណនីតេឡេក្រាម **"CEO. H.E HENG Sour" (@HENG_Souradmin)** មិនមែនជាគណនីរបស់ **ឯកឧត្តម ហេង សួរ** នោះទេ ហើយ **ឯកឧត្តមរដ្ឋមន្ត្រី** ក៏មិនមានជាប់ពាក់ព័ន្ធជាមួយនឹងក្រុមតេឡេក្រាមឈ្មោះ "ប្រាក់ចំណេញ ROI ប្រចាំថ្ងៃរបស់ OCIC ការវិនិយោគ" នោះដែរ។ **ឯកឧត្តមរដ្ឋមន្ត្រី** មិនទទួលខុសត្រូវនូវរាល់ការបាត់បង់អត្ថប្រយោជន៍ណាមួយដែលបង្កដោយគណនីតេឡេក្រាម ឬក្រុមតេឡេក្រាមខាងលើនោះឡើយ។

ក្រសួង សូមព្រមានដល់ម្ចាស់គណនីតេឡេក្រាមក្លែងក្លាយ និងម្ចាស់ក្រុមតេឡេក្រាមខាងលើ ឱ្យលុបចោលនូវគណនីតេឡេក្រាម និងរូបភាពទាំងអស់របស់ **ឯកឧត្តម ហេង សួរ** ជាបន្ទាន់។ ទន្ទឹមនឹងនេះ ក្រសួងសូមស្នើសុំអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធធ្វើការស៊ើបអង្កេត និងចាត់វិធានការតាមផ្លូវច្បាប់ឱ្យបានម៉ឺងម៉ាត់ចំពោះករណីនេះ។

អាស្រ័យដូចបានជម្រាបខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន និងបង្កើនការប្រុងប្រយ័ត្នចំពោះករណីក្លែងបន្លំនេះ។

ថ្ងៃព្រហស្បតិ៍ ៨រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៥

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩